**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**

**សំណុំរឿងព្រហ្មទណ្ឌ**
លេខ៖ ២០៣៧ អ.ក
ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១
ជំនុំជម្រះលេខ៖ ២៩៥ ជ.រ
ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២
សាលក្រមលេខ: ៧៥ (ប)
ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២២

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកណ្តាល

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តកណ្តាល

**នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ ដោយមានសមាសភាព៖**

## ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្តាល

## តំណាងអយ្យការ

លោកស្រី [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្តាល

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

## ដើម្បីជំនុំជម្រះ

**លើសំណុំរឿងព្រហ្មទណ្ឌលេខ: ២០៣៧ អ.ក ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១ ដែលមាន៖**

ជនជាប់ចោទឈ្មោះ [redacted] សំអុល ហៅ ឡូញ ភេទប្រុស អាយុ ២៥ឆ្នាំ ជនជាតិខ្មែរ មុខរបរអ្នកបើកបររថយន្តកម្រិតវប្បធម៌ថ្នាក់ទី០៩ កាន់សាសនាព្រះពុទ្ធ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូ [redacted] ខេត្តព្រៃវែង ប្រពន្ធឈ្មោះ [redacted] សាវ៉េត មានកូន ០១នាក់ ឪពុកឈ្មោះ [redacted] សំអាន (រស់) ម្តាយឈ្មោះ [redacted] យ៉ន (ស្លាប់) ទោសពីមុនគ្មាន។

**(ឃាត់ខ្លួននៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១ តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ: ៤៩៧១/២១ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល)។**

-ជាប់ចោទពីបទ: **បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឱ្យស្លាប់ និងរបួសដល់អ្នកដទៃ** ប្រព្រឹត្តនៅចំណុចកំណាត់ផ្លូវជាតិលេខ៤ ចន្លោះគីឡូម៉ែត្រ ២៧-២៨ ស្ថិតនៅភូមិទឹកជា ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៨៥ និងមាត្រា ៨៣ **នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក**។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **សំអុល** ភេទប្រុស អាយុ ២៥ ឆ្នាំ។

-ជនរងគ្រោះឈ្មោះ [redacted] **ជ័យល័ក្ខ** ភេទប្រុស អាយុ ២៧ឆ្នាំ (ស្លាប់) ដែលមានដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **នៅ** ភេទប្រុស អាយុ ៤៨ឆ្នាំ ទីលំនៅបច្ចុប្បន្ននៅភូមិត្រពាំងសុក្រំ ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល។



Scanned with CamScanner

-ជនរងគ្រោះឈ្មោះ [redacted] រត្តនា ភេទប្រុស អាយុ ២២ឆ្នាំ (របួសធ្ងន់) ដែលមានដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រេង ភេទប្រុស អាយុ ៥២ឆ្នាំ ទីលំនៅបច្ចុប្បន្ននៅភូមិត្រពាំងសុក្រំ ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្ដាល។

-ជនរងគ្រោះឈ្មោះ [redacted] ប៉េងអ៊ី ភេទប្រុស អាយុ ១៩ឆ្នាំ (របួសធ្ងន់) ដែលមានដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ខេមរិន ភេទប្រុស អាយុ ៤០ឆ្នាំ ទីលំនៅបច្ចុប្បន្ននៅភូមិត្រពាំងសុក្រំ ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្ដាល។

-លោក [redacted] ជាមេធាវីការពារសិទ្ធិអោយដើមបណ្តឹងរដ្ឋប្បវេណី។

-អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ក្រុមហ៊ុន KAP។

-បានឃើញ របាយការណ៍ស្ដីពីករណីគ្រោះថ្នាក់ចរាចរណ៍លេខ ៦៨៩ រ.ប.ក ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលស្រុកអង្គស្នួល ខេត្តកណ្ដាល។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ២៥២ ដកសព/២២ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល ។

-បានឃើញ ដីកាដំណោះស្រាយលេខ: ២៧៧ /២២ ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០២២ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកណ្ដាល។

## អង្គហេតុនៃរឿងហេតុមានដូចតទៅ៖

កាលពីថ្ងៃទី០៧ ខែ ធ្នូ ឆ្នាំ ២០២១ ម៉ោង២៣.៥០ នាទីយប់ មានរថយន្ត១គ្រឿងម៉ាកHINO ពណ៌ស ប្រភេទដឹកទំនិញពាក់ផ្លាកលេខស្វាយរៀង 3A-1178 បើកបរដោយឈ្មោះ [redacted] សំអុល ដោយដឹកសម្ភារៈគ្រឿងសំណង់ចេញពីក្រុងតាខ្មៅ ខេត្តកណ្ដាល សំដៅទៅខេត្តព្រះសីហនុ ហើយពេលបើកមកដល់ចំណុចកំណត់ផ្លូវជាតិលេខ ៤ ចន្លោះគីឡូម៉ែត្រ ២៧-២៨ ស្ថិតនៅភូមិទឹកជា ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្ដាល រថយន្តបើកបត់ឆ្វេងចូលស្ថានីយ៍ថ្លឹងរថយន្ត ស្របពេលនោះក៏មានម៉ូតូ១គ្រឿងម៉ាក HONDA សេ ១២៥ ពណ៌ខ្មៅ ពាក់ផ្លាកលេខភ្នំពេញ 1FV-7410 បើកដោយឈ្មោះ [redacted] ជ័យល័ក្ខ រួមដំណើរដោយឈ្មោះ [redacted] រតនា និងឈ្មោះ [redacted] ប៉េងអ៊ី ក្នុងទិសដៅផ្ទុយគ្នា បានបុកចំពីមុខរថយន្តចំហៀងខាងឆ្វេងបណ្តាលឲ្យឈ្មោះ [redacted] ជ័យល័ក្ខ ស្លាប់បាត់បង់ជីវិត និងបណ្តាលឲ្យឈ្មោះ [redacted] រតនា និងឈ្មោះ [redacted] ប៉េងអ៊ី រងរបួសធ្ងន់ធ្ងរ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] សំអុល បានឆ្លើយពេលសវនាការថា: នៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង ១០ យប់ ខ្លួនបានបើកឡានម៉ាក ហ៊ីណូ ជាប្រភេទឡានដឹកទំនិញ ពីទួលក្រសាំងឆ្ពោះទៅខេត្តព្រះសីហនុ លុះមកដល់ កន្លែងជញ្ជីងថ្លឹងឡានស្រុកអង្គស្នួល ខ្លួនបើកល្បឿនប្រហែល ១0KM ក្នុង ១ម៉ោង ដើម្បីថ្លឹងឡានដោយបត់ឆ្វេងវាយស៊ីញ៉ូ ខណ:ពេលនោះ ឃើញម៉ូតូ ០១គ្រឿងជិះគ្នាមាន ០៣នាក់ ជិះក្នុងទិសដៅបញ្ច្រាសគ្នាក៏បុកជាមួយឡានរបស់ខ្លួន ខ្ទាតចេញពីឡាន។ ខ្លួនក៏បានចុះទៅមើលជនរងគ្រោះសន្លប់ទាំង ០៣នាក់ ស្របពេលនោះសមត្ថកិច្ចក៏ឃាត់ខ្លួនតែម្តង។ ខ្លួនបើកឡានឲ្យក្រុមហ៊ុនផលិតទុយោជ័រ មិនស្គាល់ឈ្មោះថៅកែ។ ខ្លួនធ្វើការនៅក្រុមហ៊ុនបានរយ:ពេល ២ឆ្នាំហើយ បានប្រាក់ខែ ២៧០ដុល្លាអាមេរិក ក្នុង ១ខែ។ ខ្លួនមានប័ណ្ណបើកបរត្រឹមត្រូវ។ នៅថ្ងៃកើតហេតុ ខ្លួនមិនបានផឹកស្រាទេ



Scanned with CamScanner

ហើយក៏មិនចេះប្រើប្រាស់គ្រឿងញៀនដែរ។ ខ្លួនមិនដឹងថា ចៅកែខ្លួនផ្តល់សំណងទៅជនរងគ្រោះឬនៅទេ។ ពេលខ្លួនទៅដល់ក៏ឮសមត្ថកិច្ចនគរបាលថា ជនរងគ្រោះស្លាប់ម្នាក់ និងរបួស ០២នាក់។ ឡានរបស់ខ្លួនបើកភ្លើងធម្មតា និងមានសញ្ញាត្រីកោណ ហើយឡាននោះជារបស់ក្រុមហ៊ុម។ ម៉ូតូជនរងគ្រោះម៉ាក សង់០២០ ជិះក្នុងល្បឿនលឿន ហើយអត់បើកភ្លើងទេ ពេលខ្លួនចុះទៅមើលជនរងគ្រោះ ឃើញមានប៊ីយែរម៉ាកអាន់ឆ័រកន្លះកេះនៅលើម៉ូតូជនរងគ្រោះ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ខេមរិទ្ធ** ឆ្លើយថា: ឈ្មោះ [redacted] ម៉េងអ៊ី ជាកូនចុងរបស់ខ្លួន។ កូនរបស់ខ្លួនព្យាបាលនៅមន្ទីរពេទ្យលោកសង្ឃ ដោយបាក់កដៃខាងឆ្វេង ,របួសក្បាល និងខ្លួន ដេកព្យាបាលនៅពេទ្យប្រហែល ០៥ខែ ដោយអស់ប្រាក់ ១៦,៥លានរៀល តែខ្លួនអត់មានវិក័យប័ត្រព្យាបបាលទេ។ សព្វថ្ងៃកូនរបស់កំពុងដេកព្យាបាលនៅផ្ទះបន្ត។ ខ្លួនទាមទារប្រាក់ចំនួន ១ម៉ឺនដុល្លាអាមេរិក។ ខ្លួនឮកូនខ្លួននិយាយថា ឡានស៊ីញ៉េភ្លាមបត់ភ្លាម ហើយនៅថ្ងៃកើតហេតុ គេតេលេហ្វូនឱ្យទៅមើលភ្លើងនៅរោងបុណ្យបច្ច័យ៤។ នៅថ្ងៃកើតហេតុ កូនរបស់ខ្លួនពាក់មួកសុវត្ថិភាព អង្គុយខាងក្រោយ ហើយស្រាបៀរនោះជារបស់ម្ចាស់រោងបុណ្យទេ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **នៅ** ឆ្លើយថា ខ្លួនត្រូវជាបងថ្លៃរបស់ឈ្មោះ [redacted] ជ័យល័ក្ខ។ នៅថ្ងៃកើតហេតុ ខ្លួនមិនបានដឹងរឿងទេ។ ឈ្មោះ [redacted] ជ័យល័ក្ខ បានស្លាប់នៅកន្លែងកើតហេតុ ខ្លួនបានពិនិត្យឃើញមានរបួសនៅមុខ ,ដៃ ,ជើង ,របួសក្បាល និងបាក់ដៃជើង។ ក្រុមគ្រួសារបានយកទៅបូជារួចហើយ ខ្លួនទុកសិទ្ធិឱ្យមេធាវីរបស់ខ្លួនជាអ្នកទាមទារសំណង។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ស្រេង** ឆ្លើយថា: ខ្លួនជាឪពុកបង្កើតរបស់ឈ្មោះ [redacted] រត្តនៈ។ នៅថ្ងៃកើតហេតុ ខ្លួនមិនដឹងថា កូនរបស់ខ្លួនទៅណាទេ។ លុះព្រឹកឡើង អ្នកភូមិប្រាប់ថា កូនរបស់ខ្លួនជួបគ្រោះថ្នាក់ចរាចរណ៍។ កូនខ្លួនបែកក្បាល ,ជង្គងខាងឆ្វេង ,បាក់ដងកាំបិត១ , បែកក្បាលដេរ ជាច្រើនថ្នេរ ដោយដេកព្យាបាលនៅមន្ទីរលោកសង្ឃប្រហែល ៥-៦ខែហើយ អស់ប្រាក់ចំនួន ២៥០០ដុល្លាអាមេរិក តែបច្ចុប្បន្នកូនខ្លួនចេញពីពេទ្យហើយ។ ខ្លួនមានវិក័យប័ត្រអំពីការព្យាបាលដាក់ជូនតុលាការរួចហើយ។ ខ្លួនទាមទារសំណងពីជនជាប់ចោទ ឬក្រុមហ៊ុនចំនួន ១ម៉ឺនដុល្លាអាមេរិក។

-តាមកំណត់ហេតុចាប់យកវត្ថុតាង ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលស្រុកអង្គស្នួលផ្នែកសណ្តាប់ធ្នាប់ចរាចរណ៍ រួមមានម៉ូតូចំនួន១គ្រឿងម៉ាកហុងដាទ្រីម ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ 1FV-7410 និងរថយន្ត១គ្រឿងម៉ាក ហ៊ីណូ(HINO) ពណ៌ស ប្រភេទដឹកទំនិញ ពាក់ផ្លាកលេខ ស្វាយរៀង 3A-1178 ដែលដកហូតពីកន្លែងកើតហេតុ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីសន្និដ្ឋានថា: ឆ្លងតាមការសួរដេញ ,ស្តាប់ចម្លើយជនជាប់ចោទ ,សំបុត្រមរណភាព និងចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឃើញថា ជនជាប់ចោទបើកឡានឱ្យក្រុមហ៊ុនបានប្រាក់ខែចំនួន ២៧០ដុល្លាអាមេរិក ហើយធ្វើការនៅក្រុមហ៊ុនបានរយៈពេល ០២ឆ្នាំ។ ជនជាប់ចោទមានការធ្វេសប្រហែលក្នុងការបើកបរ ទើបធ្វើស្លាប់ និងរបួសអ្នកដទៃ។ សំណូមពរទាមទារសំណងពីជនជាប់ចោទ និងក្រុមហ៊ុន KAP សងឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីមានឈ្មោះ [redacted] ម៉េងអ៊ី ចំនួន ១០០០០(មួយម៉ឺន)ដុល្លាអាមេរិក ,ឈ្មោះ [redacted] រត្តនៈ ចំនួន ១០០០០(មួយម៉ឺន)ដុល្លាអាមេរិក និងឈ្មោះ [redacted] ជ័យល័ក្ខ ចំនួន ៥០០០០(ប្រាំ



Scanned with CamScanner

ម៉ឺន)ដុល្លាអាមេរិក និងថ្លៃសេវាមេធាវីចំនួន ១០០០០(មួយម៉ឺន)ដុល្លាអាមេរិក យោងមាត្រា ៧២ នៃច្បាប់ចរាចរណ៍ផ្លូវគោក ,មាត្រា ៧៤៧ នៃក្រមរដ្ឋប្បវេណី និងសុំប្រគល់ម៉ូតូម៉ាក ហាង់ដាឌ្រីម ឲ្យមកកូនក្តីខ្លួនវិញ ព្រមទាំងផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ ,ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីទាំង ០៣នាក់ ជនជាប់ចោទបានសារភាពថា នៅថ្ងៃកើតហេតុ ជនជាប់ចោទឈ្មោះ [redacted]សំអុល ពិតជាបានបើកបរដោយធ្វេសប្រហែលបណ្តាលឲ្យជនរងគ្រោះម្នាក់ស្លាប់ និងរបួស ០២នាក់។ មូលហេតុ ម៉ូតូបើកលឿន រីឯអ្នកបើកឡានម៉ាក ហ៊ីណូ ពណ៌ស ដឹកទំនិញពាក់ស្លាកលេខ ស្វាយរៀង 3A-1178 ដឹកសម្ភារៈគ្រឿងសំណង់ ហើយបត់ចូលកន្លែងថ្លឹងរថយន្ត ស្រាប់តែបុកម៉ូតូដែលមានទិសដៅផ្ទុយគ្នា តំណាងអយ្យការស្នើសុំតុលាការពិចារណាស្ថានភាពជាក់ស្តែង តើជាកំហុសរបស់ជនរងគ្រោះ ឬជាកំហុសរបស់ជនជាប់ចោទ ជូនតុលាការសម្រេចតាមច្បាប់កំណត់។

-លោក[redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា ក្នុងសំណុំរឿងព្រហ្មទណ្ឌនេះ ជាការពិតណាស់ មានជនរងគ្រោះម្នាក់ស្លាប់ និងរបួស ០២នាក់ ដោយសារគ្រោះថ្នាក់ចរាចរណ៍។ តាមរបាយការណ៍សមត្ថកិច្ច ជនជាប់ចោទបើកបរធ្វេសប្រហែស រីឯបើកម៉ូតូក្នុងល្បឿនលឿន ហើយម៉ូតូរបស់ជនរងគ្រោះមានស្រាបៀរ និងជិះម៉ូតូមានគ្នាចំនួន ០៣នាក់ អាចសន្និដ្ឋានថា ជនរងគ្រោះផឹកស្រា ហើយបានបើកបរ។ ជនជាប់ចោទជាកម្មករបើកឡានស៊ីប្រាក់ខែឲ្យថៅកែ បានប្រាក់ខែតិចតួចប៉ុណ្ណោះ សូមតុលាការពិចារណាអំពីសំណង និងសម្រាលទោសដល់ជនជាប់ចោទ យោងតាមមាត្រា ៩៣ និងមាត្រា ៩៤ នៃក្រមព្រហ្មទណ្ឌ ឬលើកលែងចោទ ដោយសារវិមតិសង្ស័យត្រូវបានប្រយោជន៍មកជនជាប់ចោទ។

+ជនជាប់ចោទឈ្មោះ [redacted] **សំអុល** បានសំណូមពរ សុំឲ្យតុលាការបន្ធូរបន្ថយទោស ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ឯកសារ និងភស្តុតាង

-ក្រោយពីបានពិនិត្យពិចារណា និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

១-តុលាការបានទទួលសំណុំរឿងព្រហ្មទណ្ឌ ពីចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល ដែលមានជនជាប់ចោទឈ្មោះ [redacted]**សំអុល** ភេទប្រុស អាយុ ២៥ឆ្នាំ ពីបទៈ **បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឲ្យស្លាប់ និងរបួសអ្នកដទៃ** តាមដីកាដំណោះស្រាយលេខ ២៧៧ /២២ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២ តុលាការធ្វើការជំនុំជម្រះលើជនជាប់ចោទ យោងតាមមាត្រា ២៨៩ ,មាត្រា ២៩១ និងមាត្រា ៣៤៨ នៃក្រម**នីតិវិធីព្រហ្មទណ្ឌ**។



Scanned with CamScanner

២-ផ្អែកតាមរបាយការណ៍របស់សមត្ថកិច្ច ,ចម្លើយសារភាពរបស់ជនជាប់ចោទ ,ដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងភស្តុតាង ឃើញថា នៅថ្ងៃកើតហេតុ ជនជាប់ចោទឈ្មោះ [redacted] **សំអុល** បានបើកបររថយន្តដឹកទំនិញចំនួន ១គ្រឿង ពាក់ស្លាកលេខ ស្វាយរៀង 3A-1178 ក្នុងទិសដៅពីកើតទៅលិច(ភ្នំពេញ-កំពង់ស្ពឺ) លុះដល់ចំណុចផ្លូវជាតិលេខ ៤ ស្ថិតនៅភូមិទឹកជា ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល រថយន្តបានបត់ឆ្វេងចូលស្ថានីយ៍ ដើម្បីថ្លឹង ខណៈនោះក៏មានម៉ូតូចំនួន ០១គ្រឿង ម៉ាកហុងដាឌ្រីម ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 1FV-7410 ប៉ះទង្គិចគ្នា ដែលបើកបរដោយឈ្មោះ ម៉ន ជ័យល័ក្ខ បានស្លាប់នៅនឹងកន្លែងកើតហេតុ ចំណែកឯអ្នករួមដំណើរឈ្មោះ [redacted] រត្តនៈ និងឈ្មោះ [redacted] ប៉េងអ៊ី រងរបួសធ្ងន់ កំហុសនេះមកពីអ្នកបើកបររថយន្តឈ្មោះ [redacted] សំអុល បត់ឆ្លងផ្លូវខ្វះការប្រុងប្រយ័ត្ន។ អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **សំអុល** គឺជាអង្គហេតុត្រូវនឹងបទល្មើស **បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឲ្យស្លាប់ និងរបួសអ្នកដទៃ** ដែលមានចែងតាមបញ្ញត្តិមាត្រា ៨៥ និងមាត្រា ៨៣ **នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក**។

៣-ជនជាប់ចោទឈ្មោះ [redacted] **សំអុល** មានសតិសម្បជញ្ញៈ និងសមត្ថកិច្ចគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវបទព្រហ្មទណ្ឌ នូវទង្វើរបស់ខ្លួន។

៤-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំទាមទារសំណងពីជនជាប់ចោទ និងក្រុមហ៊ុន KAP សងឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីមានឈ្មោះ [redacted] ម៉េងអ៊ី ចំនួន ១០០០០(មួយម៉ឺន)ដុល្លាអាមេរិក , ឈ្មោះ [redacted] រត្តនៈ ចំនួន ១០០០០(មួយម៉ឺន)ដុល្លាអាមេរិក និងឈ្មោះ [redacted] ជ័យល័ក្ខ ចំនួន ៥០០០០(ប្រាំម៉ឺន)ដុល្លាអាមេរិក និងថ្លៃសេវាមេធាវីចំនួន ១០០០០(មួយម៉ឺន)ដុល្លាអាមេរិក តុលាការនឹងពិនិត្យពិចារណាតាមភាពសមរម្យ និងជាក់ស្តែង យោងតាមមាត្រា ៧២ នៃច្បាប់ចរាចរណ៍ផ្លូវគោក ,មាត្រា ៧៤៧ នៃក្រមរដ្ឋប្បវេណី ,មាត្រា ២១ និងមាត្រា ៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ រីឯការស្នើសុំម៉ូតូឲ្យទៅម្ចាស់ដើមវិញ មានលក្ខណៈត្រឹមត្រូវ។

៥-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការបានស្នើសុំតុលាការពិចារណាស្ថានភាពជាក់ស្តែង តើជាកំហុសរបស់ជនរងគ្រោះ ឬជាកំហុសរបស់ជនជាប់ចោទ ចំណុចនេះជនជាប់ចោទក៏មានកំហុសដោយសារបត់ឆ្លងផ្លូវខ្វះការប្រុងប្រយ័ត្ន រីឯជនរងគ្រោះក៏មានកំហុសដែរ ដោយសារបើកបរម៉ូតូក្នុងល្បឿនលឿនខ្វះការប្រុងប្រយ័ត្ន។ ប៉ុន្តែតុលាការជំនុំជម្រះលើជនជាប់ចោទឈ្មោះ [redacted] **សំអុល** តាមដីកាដំណោះស្រាយលេខ ២៧៧ /២២ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល ពីបទ **បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឲ្យស្លាប់ និងរបួសដល់អ្នកដទៃ** តាមមាត្រា ២៨១ នៃ**ក្រមនីតិវិធីព្រហ្មទណ្ឌ**ប៉ុណ្ណោះ។

៦-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ស្នើសុំឲ្យតុលាការពិចារណាអំពីសំណង និងសម្រាលទោសដល់ជនជាប់ចោទ យោងតាមមាត្រា ៩៣ និងមាត្រា ៩៤ នៃក្រមព្រហ្មទណ្ឌ តុលាការនឹងពិនិត្យពិចារណា។

៧-មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] **សំអុល** ភេទប្រុស អាយុ ២៥ឆ្នាំ ពីបទៈ **បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឲ្យស្លាប់ និងរបួសដល់អ្នកដទៃ** ប្រព្រឹត្តនៅចំណុចកំណាត់ផ្លូវជាតិលេខ៤ ចន្លោះគីឡូម៉ែត្រ ២៧ ,២៨ ស្ថិតនៅភូមិទឹកជា ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២១ ដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៨៥ និងមាត្រា ៨៣ នៃ**ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក**។



Scanned with CamScanner

៨-អំពើដែលជនជាប់ចោទឈ្មោះ [redacted] **សំអុល** បានប្រព្រឹត្តបានធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គម ព្រមទាំងធ្វើឲ្យស្លាប់ និងរបួសអ្នកដទៃ ដូច្នេះទណ្ឌកម្ម ដែលត្រូវអនុវត្តលើជនជាប់ចោទ តុលាការនឹងពិនិត្យពិចារណា។

៩-វត្ថុចាប់យកតាមកំណត់ហេតុ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលស្រុកអង្គស្នួល ដែលបានរក្សាទុកនៅផ្នែកសណ្តាប់ធ្នាប់ចរាចរណ៍ នៃអធិការដ្ឋានស្រុកអង្គស្នួល មានៈ ម៉ូតូចំនួន ១គ្រឿង ម៉ាកហុងដា ផ្លាកលេខ ភ្នំពេញ 1FV-7410 ជារបស់ជនរងគ្រោះ គប្បីប្រគល់ឲ្យទៅម្ចាស់ដើមវិញ។ ដោយឡែករថយន្តម៉ាក ហ៊ីណូ (HINO) ពណ៌ស ប្រភេទដឹកទំនិញ ពាក់ផ្លាកលេខ ស្វាយរៀង 3A-1178 ដែលដកហូតពីកន្លែងកើតហេតុ ត្រូវបានតុលាការរក្សាការពាររឹបអូសជាបណ្តោះអាសន្នរួចហើយ ដូច្នេះរថយន្តនេះ តុលាការមិនលើកយកមកពិនិត្យសម្រេចឡើយ។

១០-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ខេមរិន្ទ** ត្រូវជាឪពុកចុងរបស់ជនរងគ្រោះឈ្មោះ [redacted] **ប៉េងអ៊ី** ប្តឹងទាមទារសំណងពីជនជាប់ចោទ និងក្រុមហ៊ុន KAP ចំនួន ១០០០០(មួយម៉ឺន)ដុល្លាអាមេរិក ,ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ស្រេង** ដែលត្រូវជាឪពុកបង្កើតរបស់ជនរងគ្រោះឈ្មោះ [redacted] **វត្តនៈ** ប្តឹងទាមទារសំណងពីចំនួន ១០០០០(មួយម៉ឺន)ដុល្លាអាមេរិក និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **នៅ** ត្រូវជាបងថ្លៃរបស់ជនរងគ្រោះឈ្មោះ [redacted] **ជ័យល័ក្ខ** និងលោកមេធាវីរបស់ខ្លួនឈ្មោះ [redacted] **ធុនណា** ប្តឹងទាមទារសំណងចំនួន ៥០០០០(ប្រាំម៉ឺន)ដុល្លាអាមេរិក និងថ្លៃសេវាមេធាវីចំនួន ១០០០០(មួយម៉ឺន)ដុល្លាអាមេរិក តុលាការនឹងពិនិត្យពិចារណាតាមភាពសមរម្យ និងជាក់ស្តែងយោងតាមមាត្រា ២១ ,មាត្រា ៣៥៥ នៃ**ក្រមនីតិវិធីព្រហ្មទណ្ឌ** ,មាត្រា ៧២ នៃ**ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក** និងមាត្រា ៧៤៧ នៃ**ក្រមរដ្ឋប្បវេណី**។

## **ហេតុដូច្នេះសម្រេច**

១/-ផ្តន្ទាទោសឈ្មោះ [redacted] **សំអុល** ភេទប្រុស អាយុ ២៥ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេលចំនួន ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៨.០០០.០០០(ប្រាំបីលាន)រៀល ពីបទៈ **បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន បណ្តាលឲ្យស្លាប់ និងរបួសដល់អ្នកដទៃ** ប្រព្រឹត្តនៅចំណុចកំណាត់ផ្លូវជាតិលេខ៤ ចន្លោះគីឡូម៉ែត្រ ២៧ ,២៨ ស្ថិតនៅភូមិទឹកជា ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៨៥ និងមាត្រា ៨៣ នៃ**ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក**។

២/-បង្គាប់ឲ្យឈ្មោះ [redacted] **សំអុល** និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីក្រុមហ៊ុន KAP រួមគ្នាផ្តល់សំណងឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីដូចខាងក្រោម៖

ក/សងទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **នៅ** ចំនួន ៣០០០០(បីម៉ឺន)ដុល្លាអាមេរិក ការទាមទារលើសពីនេះ ត្រូវច្រានចោល។

ខ/សងទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ស្រេង** ចំនួន ១០០០០(មួយម៉ឺន)ដុល្លាអាមេរិក។

គ/សងទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ខេមរិន** ចំនួន ១០០០០(មួយម៉ឺន)ដុល្លាអាមេរិក។



Scanned with CamScanner

៣/-ប្រគល់វត្ថុចាប់យកតាមកំណត់ហេតុ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលស្រុកអង្គស្នួល ដែលបានរក្សាទុកនៅផ្នែកសណ្តាប់ធ្នាប់ចរាចរណ៍ នៃអធិការដ្ឋានស្រុកអង្គស្នួល មាន: ម៉ូតូចំនួន ១គ្រឿង ម៉ាកហុងដា ផ្លាកលេខ ភ្នំពេញ 1FV-7410 ឲ្យទៅម្ចាស់ដើមវិញ។

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **សំអុល** , ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២២ រក្សាសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជី**

ហត្ថលេខា និងត្រា [redacted]

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា [redacted]

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃព្រហស្បតិ៍ ០២រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ខេត្តកណ្តាល ,ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២២

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner